**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ៖ សរ.ស.ព-០១១/១១

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**តាមរយៈ** ៖ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**កម្មវត្ថុ** ៖ ស្នើពន្យាការអនុវត្តគំរោងវារីអគ្គិសនីសេសានក្រោម II របស់ក្រុមហ៊ុនវៀតណាមឈ្មោះ EVN ហ៊ុន ជាមួយក្រុមហ៊ុន Royal Group ។

**យោង** ៖ -មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ

-អត្ថបទផ្សាយក្នុងសារព័ត៌មាន The Cambodia Daily ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១១ ។

ដោយមានការផ្សាយព័ត៌មានពីគំរោងសាងសង់វារីអគ្គិសនីសេសានក្រោម II ដែលស្ថិតក្នុងខេត្តស្ទឹងត្រែងរបស់ក្រុមហ៊ុនវៀតណាមឈ្មោះ EVN ហ៊ុនគ្នាជាមួយក្រុមហ៊ុន Royal Group របស់ឧញ៉ា **គិត ម៉េង** ដែលមានកម្លាំង ៤០០ មេហ្គាវ៉ាត់ សំរាប់ផ្គត់ផ្គង់អគ្គិសនី ៥០% ទៅប្រទេសវៀតណាម ។

សំណង់វារីអគ្គិសនីនេះនឹងប៉ះពាល់ដោយផ្ទាល់ដល់ពលរដ្ឋខ្មែរជាច្រើនពាន់នាក់ ដែលនឹងតម្រូវអោយផ្លាស់ទីលំនៅ ព្រោះទំនប់នេះនឹងធ្វើអោយលិចព្រៃ និងដីកសិកម្ម ប្រមាណ ៣ ម៉ឺនហិកតា និងភូមិចំនួន ៧ រួមទាំងបំផ្លាញជលផលក្នុងមូលដ្ឋាន ហើយធ្វើអោយប៉ះពាល់ដល់ជីវិតរស់នៅពលរដ្ឋរាប់ម៉ឺននាក់ផ្សេងទៀត ដែលកំពុងរស់នៅតាមខ្សែរទឹកខាងលើ និងខាងក្រោមទំនប់នេះ ។

ក្នុងការអភិវឌ្ឍន៍ប្រទេសចាំបាច់តម្រូវអោយគំរោងអភិវឌ្ឍន៍ផ្តល់ផលប្រយោជន៍ដល់ពលរដ្ឋមូលដ្ឋាន និងត្រូវធានាមិនប៉ះពាល់ដល់ជីវិតរស់នៅដោយផ្ទាល់ ឬដោយប្រយោលរបស់ពលរដ្ឋនោះទេ ព្រមទាំងការពារបរិដ្ឋានធម្មជាតិផង ។ ប៉ុន្តែចំពោះគំរោងវារីអគ្គិសនីសេសានក្រោម II នេះនឹងធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ពលរដ្ឋ និងបរិដ្ឋានធម្មជាតិ ដែលតម្រូវអោយរាជរដ្ឋាភិបាលធ្វើការពិនិត្យឡើងវិញនូវគំរោងវិនិយោគរបស់ក្រុមហ៊ុន EVN របស់វៀតណាមនេះ ។

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥ ២៣) ២១១ ៩៧៥ ២២០ ៦២៨ ទូរសារ : (៨៥៥ ២៣) ២២០ ៦២៨

អាស្រ័យហេតុនេះ ខ្ញុំសុំអោយមានការបំភ្លឺពីរាជរដ្ឋាភិបាលពីដំណោះស្រាយចំពោះផលប៉ះពាល់ទាំងឡាយដែលអាចនឹងកើតមានដូចរៀបរាប់ខាងលើ និងពន្យាការអនុវត្តគំរោងសិនទំរាំរាល់បញ្ហាផ្លាស់ទីលំនៅប្រជាពលរដ្ឋត្រូវបានដោះស្រាយត្រឹមត្រូវ និងបញ្ហាប៉ះពាល់បរិដ្ឋាន និងជលផលត្រូវបានធានា ។ ជាមួយគ្នានេះដែរ សុំមេត្តាផ្តល់នូវឯកសារពាក់ព័ន្ធទាំងឡាយ ដើម្បីរដ្ឋសភាអាចចូលរួមពិនិត្យ តាមដានលើការធ្វើសេចក្តីសំរេច និងកិច្ចប្រតិបត្តិរបស់រាជរដ្ឋាភិបាលស្របតាមតួនាទីជាតំណាងរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញផង ។

សូម**សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោររាប់អាន អំពីខ្ញុំ ។

**ភ្ជាប់ជាមួយ :** អត្ថបទពីសារព័ត៌មាន

**លេខ :**..៤៧៤៨..រ.ស.

ភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១

**បានឃើញ និង បញ្ជូនមក**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

"ដើម្បីពិនិត្យ" ។

ភ្នំពេញ ថ្ងៃទី ..១០... ខែ..មិថុនា. ឆ្នាំ ២០១១

ប្រធានរដ្ឋសភា

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**សុន ឆ័យ**

**តំណាងរាស្ត្រមណ្ឌលភ្នំពេញ**

**ចំលងជូន :**

-គណៈកម្មការទី ៩ នៃរដ្ឋសភា

-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល